

# ជំពូកទី៤

# មូលដ្ឋានបំណិនប្រាស្រ័យទាក់ទង

ជាទូទៅ មនុស្សគ្រប់គ្នាតែងប្រាស្រ័យទាក់ទងដោយប្រើពាក្យសម្ដី ឬសញ្ញា។ ប៉ុន្តែកុមារចាប់ផ្តើមប្រាស្រ័យទាក់ទងតាំងពីមុនពេលពួកគេរៀនបំណិនទាំងនេះ។ ការប្រាស្រ័យទាក់ទងកើតឡើងនៅពេល :-

- មនុស្សម្នាក់បានបញ្ជូនសារទៅ ហើយ។
- មនុស្សម្នាក់ទៀតបានទទួល និងឆ្លើយតបវិញ។

កុមារតូចម្នាក់បានបញ្ជូនសារតាមរយៈការកំរើកចលនារាងកាយ ការធ្វើសម្លេង ឬការផ្លាស់ប្តូរទឹកមុខ។ នៅពេលឪពុកម្តាយយល់ចលនារបស់កូន និងបានឆ្លើយតបទៅកូនវិញ នោះគឺពួកគេបានប្រាស្រ័យទាក់ទងគ្នារួចទៅហើយ។

កុមារតូចនេះបានផ្ញើសារថា :-

**នាងមានការរំជើបរំជួល**



**នាងចង់បានល្បែងលេង**




**កុមារតូចសប្បាយដោយបានឃើញម្តាយ**




មូលដ្ឋានបំណិនប្រាស្រ័យទាក់ទងបានអភិវឌ្ឍតាំងពីកុមារនៅជាទារក គឺមុនពេលក្មេងរៀននិយាយ ឬធ្វើសញ្ញា។ នៅរយៈពេលនេះ អ្នកអាចជួយកូនឱ្យដឹងថាការប្រាស្រ័យទាក់ទងធ្វើឱ្យអ្វីៗនឹងកើតឡើង។ មូលដ្ឋាននៃការប្រាស្រ័យទាក់ទងជួយនាំកូនអ្នកឱ្យរៀននិយាយ និងប្រើភាសាសញ្ញាបាន។

ជំពូកនេះ នឹងជួយអ្នកឱ្យបានយល់ដឹងនូវរបៀបដែលកូនអ្នកអាច :-

- ផ្លាស់ប្តូរវេន។
- យកចិត្តទុកដាក់ចំពោះអ្នក។
- យល់អំពីអ្នក។
- ប្រើកាយវិការ។
- ធ្វើសម្លេង។

# របៀបកុមាររៀនប្រាស្រ័យទាក់ទង

មុនដំបូងកុមារមិនបានដឹងថាខ្លួនកំពុងធ្វើអ្វីនោះទេ ទោះបីជាកុមារចេះប្រាស្រ័យទាក់ទងតាំងពីកំណើតក៏ដោយ។ កុមារកំរើករាងកាយ ធ្វើសម្លេង ឬផ្លាស់ប្តូរទឹកមុខដោយសារតែអារម្មណ៍របស់ខ្លួន។ ឧទាហរណ៍ ក្មេងយំពេលឃ្លាន ឬសើម។ យូរៗទៅ កុមារសំគាល់ឃើញថា សាររបស់ខ្លួនបានធ្វើឱ្យអ្វីៗកើតឡើង។ ពេលកុមារយំ មនុស្សម្នាក់មកមើលក្រែងមានអ្វីទាស់ខុស។ ពេលកុមារញញឹម មនុស្សធំញញឹមរកវិញ។ ដូច្នេះកុមារចាប់ផ្តើមផ្ញើសារ ដើម្បីឱ្យអ្វីៗកើតឡើង។

ការប្រាស្រ័យទាក់ទង គឺជាកត្តាមួយដ៏មានឥទ្ធិពលសំរាប់ទទួលយកអ្វីដែលយើងចង់បាន ឬត្រូវការ និងយល់នូវអ្វីៗដែលមនុស្សផ្សេងទៀតចង់បាន ឬត្រូវការ។ អ្នកអាចជួយកុមារឱ្យចាប់ផ្តើមរៀនប្រាស្រ័យទាក់ទង ដោយឆ្លើយតបទៅនឹងចលនាសម្លេង និងការផ្លាស់ប្តូរទឹកមុខរបស់កុមារ។ ប្រការនេះជួយកុមារឱ្យដឹងថា សកម្មភាពរបស់ខ្លួនមានប្រសិទ្ធភាពទៅលើអ្នកដទៃ។




### ទុកឱ្យកូនផ្លាស់វេន

ការប្តូរវេនជួយអភិវឌ្ឍកូនអ្នកក្នុងបំណិនប្រាស្រ័យទាក់ទងតាមរបៀបពីរយ៉ាង (និយាយទៅ និងឆ្លើយតបវិញ)។ នៅពេលកុមារធំបន្តិច ប្រការនេះជួយគេឱ្យចេះរបៀបធ្វើការសន្ទនាជាមួយមនុស្សដទៃទៀត។

រូបភាពនេះ មីង***ហ្វូឡា*** ជាម្តាយរបស់ក្វាមី ជួយកូន និងខ្លួនគាត់ ដើម្បីផ្តួចផ្តើមហាត់ការផ្លាស់វេនគ្នា។







**ទឹកមុខមីង*ហ្វូឡា* បានបង្ហាញថា គាត់កំពុងសួរសំណួរ**

កូនអាចរៀនកាន់តែច្រើន បើសិនជាអ្នកអាចរក្សារបៀបលេង ឱ្យទៅ-ឱ្យមក រវាងអ្នក និងកូន។

ឧទាហរណ៍: មីង***ហូឡា*** រងចាំទាល់តែ***ក្វាមី***មើលមកគាត់។ គាត់ទាក់ទាញឱ្យ***ក្វាមី***ចាប់អារម្មណ៍ និងភ្ជាប់សកម្មភាពដោយការញាក់ចញ្ចើម ញញឹមដាក់កូន និងក្រឡុកបាល់។










ឥឡូវនេះ ***ក្វាមី***បានដឹងនូវអ្វីដែលត្រូវធ្វើ។ ***ក្វាមី***និងម្ដាយបានប្ដូរវេនគ្នាទៅវិញទៅមក។

---

បន្ទាប់មកមីង***ហូឡា***បានប្ដូរទៅលេងល្បែងថ្មី ដើម្បីរក្សាចំណាប់អារម្មណ៍របស់***ក្វាមី***។ មីងលាក់បាល់ក្នុងប្រអប់មួយ។ ចូរសំគាល់ទឹកមុខរបស់មីង***ហូឡា***។

តើអ្នកគួរធ្វើទឹកមុខបែបណា ពេលសួរសំណួរដោយមិនប្រើពាក្យនិយាយ "តើបាល់នៅឯណា?"។









អ្នកបានឃើញស្រាប់ហើយនៅក្នុងរូបភាពទាំងនេះ មូលដ្ឋាននៃការប្រាស្រ័យទាក់ទងចាប់ផ្ដើមតាំងពីពេលកុមារនៅក្មេងខ្ចី។ ការប្រាស្រ័យទាក់ទងមិនចាំបាច់មានពាក្យសម្ដីឡើយ។

## លើកទឹកចិត្តកូនឱ្យចេះប្តូរវេនគ្នា

នៅពេលអ្នកប្តូរវេនជាមួយកូន វាមានការខុសប្លែកពីគ្នារាល់ៗលើក។ នេះជាការណែនាំជារួមខ្លះៗ ដើម្បីឱ្យបាន ជោគជ័យក្នុងការប្តូរវេនគ្នា។

ការចាប់ផ្តើម :-

- ទាក់ទាញចំណាប់អារម្មណ៍របស់កូន និងធ្វើឱ្យកូនដឹងថា អ្នកត្រៀមខ្លួន ដើម្បីលេងជាស្រេចហើយ។




**បើសិនជាកូនមិនឆ្លើយតបក្នុងវិធីណាមួយនោះ ចូរព្យាយាមក្រើនរំឭកកូន ដូចជាប៉ះដៃដើម្បីរំឭកថាដល់វេនកូនហើយ។**

- ឱ្យវេនកូនធ្វើមុន។ ពេលនោះអ្នកអាចឆ្លើយតបនូវអ្វីដែលធ្វើឱ្យកូនចាប់អារម្មណ៍។ តែបើអ្នកចាំយូរពេក អ្នកចាប់ផ្តើមធ្វើមុនដោយខ្លួនឯង។




**អ្នកត្រូវចាំ លុះត្រាតែកូនយកចិត្តទុកដាក់សិន មុនអនុវត្តវេនរបស់អ្នក។ បន្ទាប់មកព្យាយាមចំណាយពេល លើវេនរបស់អ្នក ឱ្យស្មើនឹងពេលនៃវេនរបស់កូន។**

- កូនអ្នកនឹងដឹងថាអ្នកបានកត់សំគាល់ ហើយមានការពេញចិត្តលើសកម្មភាពរបស់គេ។ កូនអ្នកនឹងព្យាយាមធ្វើវា ម្តងហើយម្តងទៀត ដើម្បីទាក់ទាញការឆ្លើយតបពីអ្នកវិញ។ ពេលកូនធ្វើសម្លេង ឬសញ្ញាមួយ និងទទួលបានការឆ្លើយតបជាវិជ្ជមាន កូនអ្នកនឹងចង់ធ្វើសម្លេង ឬធ្វើសញ្ញាជាច្រើនថែមទៀត។

## ពេលអ្នកឆ្លើយតបទៅកូនវិញ ចូរព្យាយាម :-

- **ធ្វើត្រាប់តាម**សម្លេង ឬសកម្មភាពកូន (បើសិនជាកូននិយាយ "កា..កា" បន្ទាប់មកអ្នកនិយាយ "កា..កា")។
- **បន្ត**ធ្វើអ្វីៗដែលកូនពេញចិត្ត (ប្រមៀលបាល់ទៅឱ្យកូនម្តងទៀត)។
- **បន្ថែម**សកម្មភាពតូចៗទៅលើអ្វីដែលកូនកំពុងធ្វើ (ដូចជាធ្វើឱ្យកូនមើលទៅរកបាល់) ដើម្បីរក្សាការយកចិត្តទុកដាក់ និងជួយកូនរៀនវិធីលេងល្បែងថ្មីៗទៀត។




**អនុញ្ញាតឱ្យកូនឈប់លេងដោយខ្លួនឯង ពេលណាដែលកូនចង់ឈប់។ ដំបូង ការលេងប្តូរវេនដោយប្រើពេលត្រឹមតែមួយ-ពីរនាទីប៉ុណ្ណោះ។ មួយសន្ទុះក្រោយមក កូនអ្នកនឹងចង់លេងប្តូរវេនគ្នាដែលមានរយៈពេលវែង។**

កុមារនឹងចេះលេងប្តូរវេនគ្នាបានច្រើន ពេលពួកគេកាន់តែធំទៅ។

កុមារធំៗដែលមិនអាចស្តាប់ឮ ក៏ត្រូវការរៀនសូត្រអំពីរបៀប ឱ្យទៅ-ឱ្យមកដែរ នៅក្នុងសកម្មភាពណាដែលពួកគេចាប់អារម្មណ៍។ ចំពោះកុមារអាយុ 5ឆ្នាំម្នាក់ ការលេងល្បែងកំសាន្តផ្សេងទៀតអាចធ្វើឱ្យគេចាប់អារម្មណ៍ ច្រើនជាងលេងប្រមៀលបាល់។



**បងស្រីរបស់*វីណេ* កំពុងបង្រៀន*វីណេ*លេងល្បែងទះដៃ។**

## ត្រៀមរៀបចំកុមារឱ្យរៀនប្រើសញ្ញា និងរៀននិយាយ

អ្នកអាចជួយកុមារឱ្យយល់ពាក្យនិងសញ្ញា ខណៈដែលកុមារសិក្សាដឹងថា ការប្រាស្រ័យទាក់ទងអាចធ្វើឱ្យអ្វីៗកើតឡើងបាន។ ប្រការនេះនឹងត្រៀមឱ្យកុមារចេះប្រើសញ្ញា និងនិយាយ។ ដើម្បីយល់ពាក្យនិងសញ្ញា ដំបូងកុមារត្រូវផ្តោតការយកចិត្តទុកដាក់លើពួកវាសិន បន្ទាប់មកកុមារត្រូវសិក្សាអំពីន័យរបស់ពាក្យ។ សូមអានជំពូកទី៨ និងទី៩ សំរាប់ការណែនាំដើម្បីជួយកុមាររៀនអត្ថន័យនៃសញ្ញានិងពាក្យ ព្រមទាំងរបៀបរៀនប្រើសញ្ញា និងពាក្យដោយខ្លួនឯង។

## លើកទឹកចិត្តកូនឱ្យប្រើចលនាដៃ

ការប្រើកាយវិការ ជាធម្មជាតិចំពោះកុមារទៅហើយ។ ទាំងមនុស្សថ្លង់ និងមនុស្សស្តាប់ឮ ការប្រើដៃ រាងកាយ និងសំដែងទឹកមុខដើម្បីប្រាស្រ័យទាក់ទង គឺត្រូវបានប្រើប្រាស់រួចទៅហើយ ទាំងមានពាក្យ និងគ្មានពាក្យ។ ចលនាទាំងនេះហៅថាកាយវិការ។ យើងគ្រវីដៃមានន័យថា "លាសិនហើយ"។ យើងគ្រវីក្បាល និងចង្អុល មានន័យថា "ទេ"។ នេះគឺជាឧទាហរណ៍អំពីកាយវិការដែលមនុស្សប្រើ :-

**បុរសម្នាក់ឆ្លើយថា គាត់មិនដឹងទេ។**

**កុមារនេះ កំពុងប្រាប់ម្តាយថា ខ្លួនត្រូវការអ្វីមួយ។**




ការប្រើកាយវិការ និងសញ្ញាមិនបានរារាំងកុមារពីការរៀននិយាយឡើយ។ **កាយវិការជួយត្រៀមរៀបចំកុមារឱ្យចេះធ្វើសញ្ញា និងនិយាយ។** ដោយសារការប្រើសញ្ញានិងកាយវិការ កុមារដឹងថា ខ្លួនអាចផ្ញើសារបានច្បាស់លាស់។ ឧទាហរណ៍ កុមារដឹងថា តាមរយៈការគ្រវីក្បាលរបស់ខ្លួន គឺគេបានបញ្ជាក់យ៉ាងច្បាស់ថា ខ្លួនគេមិនចង់ធ្វើអ្វីឡើយ។

ខណៈពេលអ្នកនៅជាមួយកូន អ្នកត្រូវឱ្យកូនប្រើកាយវិការ សញ្ញា ឬសម្លេង។ កុមារត្រូវការដឹងថា ពាក្យ និងសញ្ញារបស់ខ្លួនគឺសំខាន់ ហើយមនុស្សឆ្លើយតបចំពោះការប្រាស្រ័យទាក់ទងរបស់ខ្លួន។

- ប្រើកាយវិការឱ្យបានញឹកញាប់ដើម្បីផ្ញើសារទៅឱ្យកូន។

**មីងរបស់ *សុនីល* ប្រើកាយវិការ។**



**យាយរបស់ *ថៃលាស***
**ប្រើកាយវិការ និងពាក្យ**
**និយាយរួមគ្នា។**




- ដើម្បីប្រាស្រ័យទាក់ទង ប្រើចលនាដៃដែលកូនអ្នកបានប្រើរួចហើយ។ កុមារភាគច្រើនចាប់ផ្តើមប្រឌិតចលនាដៃ ជាឈ្មោះរបស់វត្ថុ មនុស្ស ឬសកម្មភាពនានា។ បើសិនជាអ្នកសំគាល់មើលចលនាដៃទាំងនេះ ក្រុមគ្រួសារ និងអ្នកផ្ទាល់អាចចាប់ផ្តើមបង្កើត "សញ្ញាប្រចាំផ្ទះ"។

ឧទាហរណ៍ :-

***តឿ* ចង្អុលទៅសត្វចាប**



***តឿ* ធ្វើចលនា "ហើរ"**
**ដើម្បីដាក់ឈ្មោះឱ្យចាប**



**ម្តាយ *តឿ* ប្រើចលនាដៃរបស់ *តឿ***
**បានធ្វើជាមួយគ្នានឹងពាក្យនិយាយ។**




សញ្ញាទាំងនេះមានប្រយោជន៍ណាស់ សំរាប់ឱ្យក្រុមគ្រួសារប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ប៉ុន្តែមនុស្សផ្សេងទៀតប្រហែលជាមិនយល់សញ្ញាទាំងនេះទេ។ សូមអានទំព័រ40 សំរាប់ព័ត៌មានស្តីពីសញ្ញាប្រចាំផ្ទះ។

- លេងល្បែងណា ដែលជួយឱ្យកុមារចេះចង្អុល ។




- គូររូបភាពនៃសមាជិកក្រុមគ្រួសារម្នាក់ៗ និងម្ហូបអាហារដែលកូនតែងញ៉ាំជាធម្មតា វត្ថុដែលកូនចូលចិត្តលេង និងសំលៀកបំពាក់របស់កូន ។ លើកទឹកចិត្តកូនឱ្យចង្អុលទៅអ្វីដែលកូនត្រូវការ ។



- ជួយកូនឱ្យចេះបង្ហាញអារម្មណ៍អ្វីៗដែលមានក្នុងចិត្ត ដោយប្រើកាយវិការ ។ កុមារនឹងចាំនូវកាយវិការដែលអ្នកធ្វើ និងចេះធ្វើតាមកាយវិការទាំងនោះ ។



## ការប្រាស្រ័យទាក់ទងនឹងសញ្ញាប្រចាំផ្ទះ

ពេលដែលគ្រួសារមួយមានកូនថ្លង់ម្នាក់ កាយវិការជួយមនុស្សក្នុងគ្រួសារនោះឱ្យចាប់ផ្តើមប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក។ ប៉ុន្តែមនុស្សយើងត្រូវការវិធីពេញលេញដើម្បីប្រាស្រ័យទាក់ទងគ្នា ជាងកាយវិការសាមញ្ញៗ។ ជាញឹកញាប់ ក្រុមគ្រួសារទាំងឡាយបានបង្កើតនិងប្រើ "សញ្ញាប្រចាំផ្ទះ" ពួកគេអភិវឌ្ឍចលនាដៃនិងរាងកាយ ដើម្បីសំដែងអារម្មណ៍ខ្លួនឯង និងដើម្បីប្រាស្រ័យទាក់ទងជាមួយកូនថ្លង់របស់ពួកគេ។ នេះជាឧទាហរណ៍មួយ :-

បុរសជនជាតិម៉ិចស៊ិចកូម្នាក់ បានទៅភូមិមួយជាមួយកូនប្រុសថ្លង់អាយុ៦ឆ្នាំ។ ពេលកូនរបស់គាត់ចង់ត្រឡប់ទៅផ្ទះវិញ ក្មេងនោះបានចាប់ទាញខោឪពុករបស់ខ្លួន។ បន្ទាប់មកក្មេងតូចប្រើសញ្ញាប្រចាំផ្ទះ ដែលខ្លួនគេ និងក្រុមគ្រួសារបានប្រឌិតឡើង។






**កុមារនេះទាញខោឪពុក ចង្អុល និងប្រើសញ្ញាប្រចាំផ្ទះរួមគ្នា "ជិះសត្វលា" និង "សូម"។**

**ករណីនេះ ជួយឱ្យកុមារប្រាស្រ័យទាក់ទងបានច្រើន ដោយប្រើតែកាយវិការសាមញ្ញមួយមុខគត់។**

ការបង្កើត និងប្រើសញ្ញាប្រចាំផ្ទះ គឺជារឿងធម្មតាសំរាប់គ្រួសារដែលមានកូនថ្លង់ ឬមិនអាចស្តាប់ឮ។ មនុស្សថ្លង់ និងមនុស្សស្តាប់ឮដទៃទៀត ប្រហែលជាមិនយល់សញ្ញាដែលអ្នកបានប្រឌិត ប៉ុន្តែអ្នកអាចចែករំលែកសញ្ញាទាំងនោះ ជាមួយមិត្តភក្តិ ដូចដែលអ្នកធ្លាប់ធ្វើជាមួយក្រុមគ្រួសារអញ្ចឹងដែរ។

ឥឡូវនេះក្រុមគ្រួសារ និងកូនអ្នកប្រហែលជាកំពុងប្រើកាយវិការ និងសញ្ញាប្រចាំផ្ទះ។ ជាការត្រឹមត្រូវក្នុងការបន្តអនុវត្តបែបនេះ។ ទោះបីជាសញ្ញាប្រចាំផ្ទះមិនបានក្លាយជាភាសាមួយពេញលេញក៏ដោយ តែវាមានសារៈប្រយោជន៍ណាស់ចំពោះការបញ្ចេញគំនិតសាមញ្ញៗ និងជាកិច្ចចាប់ផ្តើមការប្រាស្រ័យទាក់ទងល្អមួយ។ ដើម្បីរៀនបន្ថែមពីការបង្រៀនកូនអ្នកអំពីភាសាសញ្ញាដែលប្រើនៅស្រុកភូមិរបស់អ្នករស់នៅ សូមអានជំពូកទី៨។

### ការប្រឌិតសញ្ញាប្រចាំផ្ទះ

ការប្រឌិតសញ្ញាអាចជាការសប្បាយរីករាយ។ ត្រូវចាំថា វាទាមទារពេលច្រើន និងការអត់ធ្មត់។ ប៉ុន្តែអ្នកនឹងបានផលល្អ ខណៈដែលកូននិងអ្នកចាប់ផ្តើមយល់គ្នាទៅវិញទៅមក។ នៅទំព័របន្តបន្ទាប់ខាងមុខនេះ មានផ្តល់គំនិតសំរាប់ប្រឌិតសញ្ញា។ អ្នកអាចផ្លាស់ប្តូរវាឱ្យសមស្របនឹងកាយវិការ ទំនៀមទម្លាប់ និងភាសានៃតំបន់របស់អ្នក។ ក្រុមគ្រួសារ និងអ្នកនឹងមានគំនិតជាច្រើន សំរាប់ការបង្កើតសញ្ញាប្រចាំផ្ទះរបស់ខ្លួន។

យោបល់ខ្លះៗដើម្បីជួយអ្នកឱ្យចេះចាប់ផ្តើម :-

1. ព្យាយាមធ្វើសញ្ញាឱ្យដូចវត្ថុ ឬសកម្មភាព ដែលអ្នកចង់ប្រាស្រ័យទាក់ទង ។


ទារក

**នេះជាសញ្ញាសំរាប់ "ទារក" ដែលដូចមនុស្សម្នាក់ កំពុងបីទារកក្នុងដៃ ។**



2. សំគាល់មើលសញ្ញាកូនអ្នកបានប្រឌិត និងប្រើពួកវា ។ ឧទាហរណ៍ កុមារជាច្រើនបានប្រឌិតសញ្ញា ដើម្បីឱ្យឈ្មោះ មនុស្សនៅក្នុងគ្រួសារ ។


ម៉ារីយ៉ា

**កុមារម្នាក់បានប្រឌិតឈ្មោះ សញ្ញានេះ សំរាប់ប្អូនស្រី នាងឈ្មោះម៉ារីយ៉ា ដោយ សារម៉ារីយ៉ាពាក់វ៉ែនតា ។**

3. ប្រើទ្រង់ទ្រាយដៃ កំណត់ទីតាំង និងចលនាដើម្បីប្រឌិតសញ្ញាខុសៗពីគ្នា ។ ឧទាហរណ៍ ពេលប្រឌិតសញ្ញាហូបទឹកនឹង ពែង អ្នកអាចធ្វើ...

**ធ្វើទម្រង់ដៃដូចពែងមួយ បន្ទាប់មកលើកដៃ ធ្វើដូចជាអ្នកកំពុងហូបទឹកនឹងពែង ។**


ផឹក ឬ ហូបទឹក (ពីពែង)

**ឬ បើសិនជាអ្នកចង់ប្រឌិតសញ្ញា ហូបទឹក ដោយប្រើដៃក្បង់ទឹក អ្នកអាចប្តូរទម្រង់ដៃ ឱ្យដូចរូបភាពខាងក្រោមនេះ**


ផឹក ឬ ហូបទឹក (ក្បង់ដៃ)

4. សាកល្បងបង្កើតសញ្ញាស្រដៀងគ្នា សំរាប់សកម្មភាព ឬវត្ថុនៅក្នុងក្រុមស្របគ្នា ។ ឧទាហរណ៍ :-


ឈរ


ទម្រេត


លោត

អ្នកអាចបង្កើតសញ្ញាស្រដៀងគ្នាសំរាប់ពាក្យផ្ទុយដូចជា "រុញ" និង "ទាញ" ។

5. បញ្ចូលសញ្ញារួមគ្នាដើម្បីបង្កើតឃ្លាល្បះ សំរាប់វត្ថុ សកម្មភាព និងគំនិត ។ កុមារម្នាក់ ដែលចេះបញ្ចូលគំនិតរួមគ្នាមានបំណិន ប្រាស្រ័យទាក់ទងបានពេញលេញ ។

**"ដាក់ពែងលើតុ"**


ពែង ពែងលើតុ

# សញ្ញាជាឧទាហរណ៍

សញ្ញាទាំងនេះភាគច្រើនគឺជាភាសាសញ្ញាកម្ពុជា និងមានសញ្ញាកម្ទីខ្លះពីភាសាសញ្ញាអាមេរិក ដោយអាស្រ័យលើការប្រើប្រាស់នាពេលបច្ចុប្បន្ន។ អ្នកនឹងឃើញថា វាអាចជាគំនិតដែលមានប្រយោជន៍សំរាប់បង្កើតសញ្ញាប្រចាំផ្ទះរបស់អ្នកពីសញ្ញាទាំងនេះ រួមគ្នានឹងភាសាសញ្ញាក្នុងស្រុកភូមិរបស់អ្នក។ ឧទាហរណ៍ទាំងនេះ បានបង្ហាញសញ្ញាពិតជាច្រើនប្រភេទ ដែលក្មេងត្រូវការរៀនដើម្បីប្រាស្រ័យទាក់ទង។

## សញ្ញាសំរាប់មនុស្ស




## សញ្ញាសំរាប់វត្ថុ




## សញ្ញាសំរាប់ពិពណ៌នា



ឧទាហរណ៍ទាំងនេះ បង្ហាញរបៀបដែលសញ្ញានីមួយៗអាចផ្លាស់ប្តូរបាន និងអាចបញ្ចូលជាមួយសញ្ញាដទៃ ដើម្បីផ្តល់អត្ថន័យថ្មីៗទៀត។

## សញ្ញាសំរាប់ធ្វើសកម្មភាព

**អំពីការធ្វើអ្វីមួយ** **អំពីការគិត** **អំពីការផ្សារភ្ជាប់ទៅមនុស្សដទៃទៀត**




## សញ្ញាសំរាប់សួរសំណួរ




## សញ្ញាសំរាប់ទិសដៅ




## សញ្ញាសំរាប់ពេលវេលា



## លើកទឹកចិត្តកូនឱ្យបញ្ចេញសម្លេង

កុមារចាប់ផ្តើមប្រើចលនាដៃ និងកាយវិការតាំងពីនៅជាទារក សកម្មភាពទាំងនេះអាចក្លាយជាមូលដ្ឋានសំរាប់អភិវឌ្ឍការប្រាស្រ័យទាក់ទង និងភាសាសញ្ញា។ កុមារក៏ចាប់ផ្តើមបញ្ចេញសម្លេង និងចេះធ្វើសូរសម្លេងតាំងពីនៅជាទារក ហើយសកម្មភាពទាំងនេះអាចក្លាយជាមូលដ្ឋាននៃការប្រាស្រ័យទាក់ទង និងការអភិវឌ្ឍភាសានិយាយផងដែរ។

កូនអ្នកត្រូវការរៀនដើម្បីដឹងថា មនុស្សធ្វើសម្លេងនឹងបបូរមាត់ អណ្តាត ដង្ហើម និងភាពខ្វះក្នុងបំពង់ក និងច្រមុះ។ បង្រៀនកូនអំពីរបៀបដែលសម្លេងបានបន្លឺក្នុងរាងកាយរបស់គេ របៀបទប់ដង្ហើម និងរបៀបបត់បែនបបូរមាត់ និងអណ្តាត ដើម្បីធ្វើសម្លេងខុសៗគ្នា។

លើកទឹកចិត្តកូនឱ្យធ្វើត្រាប់តាម ពេលអ្នកអនុវត្តសកម្មភាពនានាដូចខាងក្រោម។ វាអាចជាការពិបាកសំរាប់កុមារថ្លង់រៀនធ្វើសម្លេង។ ដូច្នេះពេលកុមារបានធ្វើសម្លេង សូមប្រាប់ឱ្យកុមារដឹងថា គេបានធ្វើកិច្ចការសំខាន់មួយ។

- ដាក់កុមារផ្តេកលើដើមទ្រូងរបស់អ្នក។ ដំបូង ធ្វើឱ្យកុមារទទួលអារម្មណ៍ថា ដើមទ្រូងរបស់អ្នកកំពុងផឹតផតតាមការដកដង្ហើមធម្មតារបស់អ្នក ដោយគ្មានការនិយាយ។

បន្ទាប់មកអ្នកនិយាយ ឬច្រៀង។ ឱ្យកូនទទួលអារម្មណ៍ប្លែកៗពីគ្នានៃចលនាដើមទ្រូងរបស់អ្នក។




លើកទឹកចិត្តកូនឱ្យយកដៃប៉ះខ្យល់ដង្ហើម ដែលចេញតាមមាត់របស់អ្នកផងដែរ។



- និយាយឱ្យជិតត្រចៀកកុមារក្នុងសម្លេងធម្មតា (ប្រមាណ៥សង់ទីម៉ែត្រ)។ ការនិយាយជិតត្រចៀកបែបនេះធ្វើឱ្យងាយស្តាប់ឮ។ កូននឹងដឹងតាមរយៈអារម្មណ៍នៃដង្ហើមរបស់អ្នក ខណៈដែលអ្នកកំពុងនិយាយផងដែរ។



- ប្រឌិតសម្លេងដែលងាយមើលឃើញលើបបូរមាត់របស់អ្នក និងធ្វើសម្លេងនោះដដែលៗឱ្យបានញឹកញាប់នៅពេលថ្ងៃ។




- ព្យាយាមតម្រូវសម្លេងមួយ ទៅនឹងវត្ថុមួយ។







**សរសើរកុមារ ពេលកុមារធ្វើសម្លេង ឬនិយាយពាក្យមួយ។**

- ព្យាយាមតម្រូវប្រវែងនៃសញ្ញាមួយ ទៅនឹងចលនាមួយ...

...ឬប្រវែងនៃពាក្យមួយ ទៅចលនាមួយ។






## 46 មូលដ្ឋានបំណិនប្រាស្រ័យទាក់ទង

លើកទឹកចិត្តកុមារឱ្យធ្វើសម្លេងដោយសរសើរក្មេងភ្លាមៗ ខណៈដែលកូនបានធ្វើសម្លេងមួយ ឬនិយាយពាក្យមួយ ។ ការសរសើរតិចតួចគឺវាគ្រប់គ្រាន់ហើយ អ្នកអាចប្រើការញញឹមជាការសរសើរកូន ។ ឬក៏ចង្អុលទៅត្រចៀករបស់អ្នក ហើយនិយាយថា "ពុកបានឮកូនហើយ" ។ ឬងក់ក្បាល ឬក៏និយាយថា "បាទ" ។ ត្រូវចាំថា វាពិបាកណាស់សំរាប់កូនរៀននិយាយឱ្យបានច្បាស់ល្អ និងប្រាស្រ័យទាក់ទងដោយប្រើពាក្យនិយាយ ។




---

នេះជាវិធីបីយ៉ាងដែលអ្នកបង្ហាញកូនថា អ្នកកំពុងយកចិត្តទុកដាក់នឹងសម្លេងរបស់កូន :-

- អ្នកអាចធ្វើត្រាប់តាមដោយបង្ហាញកូនថា អ្នករីករាយនឹងធ្វើត្រាប់តាមគេ ។ ឧទាហរណ៍ បើសិនជាកូននិយាយថា "អ៊ូ" បន្ទាប់មកអ្នកត្រូវធ្វើដូច្នេះដែរ ហើយចាំមើល បើសិនជាកូនធ្វើម្តងទៀត ។
- អ្នកឆ្លើយតបទៅសម្លេងកូនវិញ ដូចដែលអ្នកកំពុងចាប់ផ្តើមការសន្ទនាអញ្ចឹងដែរ ។ ព្យាយាមយល់អ្វីៗដែលកូនកំពុងប្រាស្រ័យទាក់ទងមករកអ្នក និងឆ្លើយតបទៅកូនវិញ ។




- អ្នកអាចសួរកូនអំពីអ្វីដែលកូនកំពុងប្រាស្រ័យទាក់ទង ។ វានឹងជួយលើកទឹកចិត្តដល់កូនឱ្យផ្តើមកិច្ចសន្ទនា ។ ក្រៅពីសួរសំណួរទៅកូន វិធីល្អមួយទៀតគឺលើកទឹកចិត្តកូនឱ្យសួរមកអ្នកវិញ ។

> នៅពេលកូនអ្នកបានអភិវឌ្ឍមូលដ្ឋានបំណិនប្រាស្រ័យទាក់ទង នោះមានន័យថា កូនបានត្រៀមរៀនភាសារួចទៅហើយ ។ ព័ត៌មានបន្ថែមស្តីពីការរៀនភាសា សូមអានជំពូកទី7 ។ សូមអានជំពូកទី8 ស្តីពីព័ត៌មានរៀនភាសាសញ្ញា និងជំពូកទី9 ស្តីពីព័ត៌មានរៀនភាសានិយាយ ។